**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងពាណិជ្ជកម្ម**

លេខ ១០១១ ព.ណ.ន.ផល

ថ្ងៃអង្គារ ៦កើត ខែចេត្រ ឆ្នាំខាល ចត្វាស័ក ព.ស.២៥៦៦

រាជធានីភ្នំពេញ ថ្ងៃទី២៨ ខែមីនា ឆ្នាំ ២០២៣

# សេចក្តីជូនដំណឹង

ក្រសួងពាណិជ្ជកម្ម បានដំណើរការអនុវត្តគម្រោង "ការកសាងសមត្ថភាពឌីជីថល និងការជំរុញផលិតផលខ្មែរទៅកាន់ទីផ្សារអន្តរជាតិតាមរយៈ CambodiaTrade.com" ក្រោមជំនួយហិរញ្ញប្បទានរបស់គណៈកម្មាធិការគ្រប់គ្រងមូលនិធិ ស.អ ដើម្បីធ្វើឌីជីថលូបនីយកម្មអាជីវកម្មខ្នាតតូច និងមធ្យម និងផ្សព្វផ្សាយផលិតផលខ្មែរលើឆាកអន្តរជាតិ ដែលគម្រោងនេះមានរយៈពេលអនុវត្ត២ឆ្នាំ។ តាមរយៈគម្រោងនេះ ក្រសួងពាណិជ្ជកម្មនឹងរៀបចំវគ្គបណ្តុះបណ្តាលដល់ម្ចាស់អាជីវកម្មចំនួន ៤វគ្គក្នុងមួយឆ្នាំ ដោយក្នុងមួយវគ្គក្រសួងនឹងជ្រើសរើសអ្នកចូលរួម ចំនួន៨០នាក់ ដើម្បីពង្រឹងសមត្ថភាពម្ចាស់អាជីវកម្មក្នុងការធ្វើប្រតិបត្តិការពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិកបានស្ទាត់ជំនាញ ជាពិសេសតាមរយៈផ្សារខេមបូឌាត្រេដ (CambodiaTrade.com)។

## ១. គោលបំណង

គោលបំណងចម្បងរបស់គម្រោង គឺដោះស្រាយបញ្ហារបស់អាជីវកម្មខ្នាតតូច និងមធ្យម នៅកម្ពុជាតាមរយៈការបង្កើនសមត្ថភាពឌីជីថល ការលើកកម្ពស់វត្តមានផលិតផលខ្មែរលើឆាកអន្តរជាតិ និងការបណ្តុះបណ្តាលអ្នកបញ្ជាទិញ និងជំរុញការបញ្ជាទិញ។ បច្ចុប្បន្ននេះ ឌីជីថលូបនីយកម្មបានក្លាយទៅជាចំណែកមួយយ៉ាងសំខាន់នៃដំណើរការប្រត្តិបត្តិការរបស់អាជីវកម្មខ្នាតតូច និងមធ្យមក្នុងការប្រកួតប្រជែងទីផ្សារទាំងក្នុង និងក្រៅប្រទេស ដោយហេតុនេះយើងមិនអាចឱ្យរបាំងបច្ចេកវិទ្យាឌីជីថលក្លាយជាកត្តារាំងស្ទះដល់ការធ្វើបរិវត្តកម្មពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក (e-commerce) បានឡើយ។ អាជីវកម្មខ្នាតតូច និងមធ្យមទាំងអស់ត្រូវពង្រឹងចំណេះដឹងលើការគ្រប់គ្រងហាងក្នុងផ្សារអេឡិចត្រូនិក និងការធ្វើមាតិកាឌីជីថលស្តង់ដាអន្តរជាតិឱ្យបានច្បាស់លាស់ ដើម្បីឱ្យផលិតផលខ្មែរអាចប្រកួតប្រជែងនៅលើទីផ្សារសកល។

## ២. អត្ថប្រយោជន៍

អាជីវកម្មខ្នាតតូច និងមធ្យម ដែលចូលរួមក្នុងវគ្គបណ្តុះបណ្តាលនឹងទទួលបានអត្ថប្រយោជន៍ដូចខាងក្រោម៖

- កាត់បន្ថយគម្លាតឌីជីថលសម្រាប់សហគ្រាសក្នុងស្រុក
- ការបង្កើនប្រសិទ្ធភាពពាណិជ្ជកម្មតាមរយៈបច្ចេកវិទ្យា ICT និងប្រែក្លាយកម្ពុជាទៅជាសេដ្ឋកិច្ចឌីជីថលតាមរយៈការធ្វើពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក (Cross-Border E-Commerce)
- ការធានាលើទំនុកចិត្តពីប្រព័ន្ធបញ្ជាទិញអនឡាញដែលច្បាស់លាស់ សំរាប់ផលិតផលខ្មែរទៅកាន់ទីផ្សារអន្តរជាតិ
- ការផលិតមាតិកាឌីជីថលស្តង់ដារ និងការដាក់លក់ផលិតផលលើ CambodiaTrade.com
- ការថតរូបតាមស្តង់ដាទីផ្សារអន្តរជាតិសម្រាប់ផ្សព្វផ្សាយផលិតផល



ឡូត៍លេខ ១៩-៦១ មហាវិថីសហព័ន្ធរុស្ស៊ី ភូមិទឹកថ្លា សង្កាត់ទឹកថ្លា ខណ្ឌសែនសុខ រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា ទូរស័ព្ទ / ទូរសារ: (៨៥៥)-២៣ ៨៦៦ ៤៦៩
Lot 19-61, Russian Federation Blvd, Phum Teuk Thla, Sangkat Teuk Thla, Khan Sen Sok, Phnom Penh, Kingdom of CAMBODIA Phone/Facsimile: (855)-23 866 469

- យុទ្ធសាស្ត្រកំណត់តម្លៃរាយ និងជាកញ្ចប់
- ការបណ្តុះបណ្តាលផ្នែកទូទាត់ និងការដឹកជញ្ជូនអន្តរជាតិ
- ការប្រឹក្សាយោបល់ និងបង្វឹកបង្ហាត់លើការធ្វើពាណិជ្ជកម្មនៅលើផ្សារ CambodiaTrade.com
- ការចូលរួមយុទ្ធនាការផ្សព្វផ្សាយថ្នាក់ជាតិដែលក្រសួង និងដៃគូសហការរៀបចំ
- ការចូលរួមពិព័រណ៍អន្តរជាតិបីដងក្នុងមួយឆ្នាំ (ក្នុងកំឡុងពេលអនុវត្តគម្រោង)

៣. លក្ខខណ្ឌក្នុងការចូលរួម

**អាជីវកម្មខ្នាតតូច និងមធ្យម ត្រូវមានលក្ខណៈសម្បត្តិដូចខាងក្រោម៖**

- ជាអាជីវកម្មខ្នាតតូច និងមធ្យម ដែលមានទីតាំងច្បាស់លាស់
- បានចុះបញ្ជីពាណិជ្ជកម្ម ឬមានបំណងចុះបញ្ជីពាណិជ្ជកម្ម
- មានបញ្ជីការបញ្ជាក់អំពីសុវត្ថិភាពក្នុងការប្រើប្រាស់ ឬឯកសារបញ្ជាក់សុវត្ថិភាពជាផ្លូវការផ្សេងៗ
- មានមូលដ្ឋានចំណេះដឹងផ្នែកឌីជីថលក្នុងការត្រៀមខ្លួនចូលរួមជាមួយផ្សារ CambodiaTrade.com (ទូរស័ព្ទឆ្លាតវៃ និងតំណភ្ជាប់អ៊ីនធឺណិត)
- សមាសភាពសិក្ខាកាមដែលចូលរួមមិនអាចផ្លាស់ប្តូរបានឡើយ
- អាជីវកម្មខ្នាតតូច និងមធ្យមដែលចូលរួមវគ្គបណ្តុះបណ្តាលតម្រូវអោយនាំយកផលិតផលមកជាមួយ ដើម្បីក្រុមការងារជួយសម្រួលក្នុងការថតផលិតផលដាក់ក្នុងផ្សារ CambodiaTrade.com
- អាជីវករជាស្ត្រី ក្រុមយុវជន និងជនមានពិការភាព ឬមានកម្រិតផ្នែកកាយសម្បទា ត្រូវបានលើកទឹកចិត្តក្នុងការដាក់ពាក្យ។

**៤. ដំណើរការដាក់ពាក្យ ការជ្រើសរើស និងកាលបរិច្ឆេទទទួលពាក្យ**

- ម្ចាស់អាជីវកម្មត្រូវបំពេញពាក្យ និងដាក់ពាក្យស្នើសុំ
- កាលបរិច្ឆេទបើកទទួលពាក្យចាប់ពីថ្ងៃទី២៣ ខែមីនា ឆ្នាំ២០២៦ និងបិទទទួលពាក្យស្នើសុំត្រឹម **ថ្ងៃទី៣១ ខែមីនា ឆ្នាំ២០២៦ វេលាម៉ោង១៧:០០នាទី**
- អ្នកចូលរួមទាំងអស់ត្រូវបំពេញពាក្យស្នើសុំដែលអាចទាញយកពី QR Code ខាងក្រោម និងដាក់ពាក្យមកកាន់ក្រុមការងារក្រសួងពាណិជ្ជកម្មតាមរយៈ លោកស្រី ម៉ៅ កញ្ញា តេឡេក្រាមលេខ ០១៧ ៩៣៥ ៥៥២ ឬអ៊ីម៉ែល mao.kannha@moc.gov.kh។

អាស្រ័យដូចបានជម្រាបជូនខាងលើ ក្រសួងពាណិជ្ជកម្ម សូមអញ្ជើញអាជីវកម្មខ្នាតតូច និងមធ្យម ឬអាជីវករទាំងអស់ ដែលមានផលិតផលក្នុងស្រុក និងមានបំណងអភិវឌ្ឍន៍អាជីវកម្មរបស់ខ្លួនតាមបែបឌីជីថល ដាក់ពាក្យស្នើសុំចូលរួមក្នុងគម្រោង "ការកសាងសមត្ថភាពឌីជីថល និងការជំរុញផលិតផលខ្មែរទៅកាន់ទីផ្សារអន្តរជាតិតាមរយៈ CambodiaTrade.com" ឱ្យបានទាន់ពេលវេលា។ អាជីវកម្មដឹកនាំដោយស្ត្រី ក្រុមយុវជន និងជនដែលមានពិការភាព ឬមានកម្រិតផ្នែកកាយសម្បទា ត្រូវបានលើកទឹកចិត្តក្នុងការចូលរួមជាមួយគម្រោងនេះ។

ក្នុងករណីមានចម្ងល់ផ្សេងៗពាក់ព័ន្ធនឹងការផ្សព្វផ្សាយជ្រើសរើសចូលរួមក្នុងគម្រោងនេះ សូមមេត្តាទាក់ទងតាមរយៈ លោកស្រី ម៉ៅ កញ្ញា ទូរស័ព្ទលេខ ០១៧ ៩៣៥ ៥៥២ (តេឡេក្រាម) ។

**សូមអរគុណ!**

QR Code ចុះឈ្មោះ



៧.០៤